## រឿងទី៥៖ ពិធីមង្គលការនៅកាណា

**ខគម្ពីរ៖ យ៉ូហាន២៖៥**

៥ មាតារបស់ព្រះអង្គប្រាប់ទៅពួកអ្នកបំរើថា៖ «បើលោកប្រាប់អោយធ្វើអ្វី ចូរធ្វើតាមទៅ»។

កាលពីយូរលង់មកហើយ មានគេរៀបចំពិធីមង្គលការនៅភូមិកាណា ក្នុងស្រុកកាលីឡេ។
ពួកសិស្ស ព្រះយេស៊ូ និងម៉ារីជាមាតាទ្រង់ ក៏បានចូលរួមពិធីមង្គលការនោះដែរ។
ភ្ញៀវទាំងអស់បានចំណាយពេលវេលាដ៏ល្អ និងរីករាយជាមួយនឹងការផឹក និងបរិភោគអាហារឆ្ងាញ់ៗ។
ពេលមនុស្សទាំងអស់កំពុងតែចំណាយពេលវេលាដ៏ល្អសុខៗ ស្រាប់តែអ្នកបម្រើបានរត់មក ប្រាប់ចៅហ្វាយថា៖
"វិវហើយ! អស់ស្រាទាំងបាយជូរហើយ! ភ្ញៀវបានមកច្រើនលើសពីការរំពឹងទុក ដូច្នេះស្រាមិនសល់សូម្បី មួយ ដំណក់!"
កំឡុងពេលអ្នកទទួលខុសត្រូវលើពិធីមង្គលការកំពុងព្យាយាមដោះស្រាយបញ្ហា ដោយអស់សង្ឃឹម ម៉ារីមាតា ព្រះយេស៊ូបានដឹងពីការនេះ។
ដូច្នេះនាងក៏បានដើរទៅកាន់ព្រះយេស៊ូ។ នាងជឿថាព្រះយេស៊ូប្រាកដជាជួយ។
ដូច្នេះហើយនាងបាននិយាយទៅកាន់ពួកអ្នកបម្រើឱ្យធ្វើអ្វីតាមតែទ្រង់បង្គាប់ទៅ។
ព្រះយេស៊ូនិងអ្នកបម្រើបានទៅក្បែរកន្លែងដែលគេរៀបចំពិធីមង្គលការ។ នៅទីនោះ មានពាងប្រាំមួយ។
ពាងទាំងនោះ គេប្រើសម្រាប់ដាក់ទឹកទុកលាងដៃពេលត្រឡប់មកក្នុងផ្ទះវិញ ឬសម្រាប់លាងចាន។
ព្រះយេស៊ូមានព្រះបន្ទូលទៅកាន់ពួកអ្នកបម្រើថា៖ «សុំដងទឹកមកចាក់ឱ្យពេញពាងទាំងនេះទៅ»។
ពួកអ្នកបម្រើមិនយល់ពីអ្វីដែលព្រះយេស៊ូមានព្រះបន្ទូលឡើយ។
ប៉ុន្តែពួកគេបានចាប់ផ្ដើមចាក់ទឹកបំពេញពាងតាមបង្គាប់ព្រះយេស៊ូ។ ហើយពួកអ្នកបម្រើបានយកស្រាទំពាំងបាយជូរទៅឱ្យចៅហ្វាយ។
ចៅហ្វាយបានភ្លក់ស្រាដែលពួកអ្នកបម្រើបានយកមក ហើយស្រាប់តែប្រែទឹកមុខរីករាយឡើង!
គាត់មិនបានដឹងថា ស្រាទំពាំងបាយជូរបានមកពីណាឡើយ ប៉ុន្តែបានដើរទៅកាន់កូនកំលោះដោយក្ដីរីករាយ!
រួចបាននិយាយថា៖ «អ្នកផងទាំងពួងតែងយកស្រាទំពាំងបាយជូរឆ្ងាញ់មកជូនភ្ញៀវជាមុន លុះភ្ញៀវពិសាច្រើនហើយ
ទើបគេយកស្រាមិនសូវឆ្ងាញ់មកជូនតាមក្រោយ។ រីឯអ្នកវិញ ម្ដេចក៏ទុកស្រាឆ្ងាញ់មកទល់ឥឡូវដូច្នេះ!»
នៅថ្ងៃនោះ ភ្ញៀវទាំងអស់ដែលបានចូលរួមពិធីមង្គលការបានផឹកស្រាទំពាំងបាយជូរដ៏ល្អបំផុត ដោយក្ដីរីករាយ។
ហើយមានពេលវេលាដ៏សប្បាយរីករាយរហូតដល់ចប់ពិធី។



**សកម្មភាពទី១** ដើម្បីរកចម្លើយសម្រាប់សំណួរទី១ សូមតម្រៀបអក្សរក្នុងប្រអប់ដែលមានលេខ១។ សូមប្រើវិធីដូចគ្នានេះ ដើម្បីរកចម្លើយសម្រាប់សំណួរបន្តបន្ទាប់ផងដែរ។

| | | | |
|---|---|---|---|
| 1 ភូ | 2 ស្រា | 1 មិ | 2 បាយ |
| 2 ជូរ | 3 ក | 4 អ | 1 ណា |
| 3 ទឹ | 4 ស្ចា | 2 ពាំ | 4 រ្យ |
| 4 ការ | 2 ទំ | 1 កា | 2 ង |

១. តើពិធីមង្គលការនេះត្រូវបានធ្វើឡើងនៅក្នុងភូមិណា? (1)

..............................................................................

២. តើគេខ្វះអ្វីនៅក្នុងពិធីមង្គលការនោះ? (2)

..............................................................................

៣. តើពួកអ្នកបម្រើបានចាក់អ្វីទៅក្នុងពាង? (3)

..............................................................................

៤. តើព្រឹត្តិការណ៍ដែលព្រះយេស៊ូបានប្រែក្លាយទឹកទៅជាស្រាទំពាំងបាយជូរនោះ គេហៅថាអ្វី? (4)

..............................................................................

- សូមអានខគម្ពីរខាងក្រោម រួចទន្ទេញ។ (យ៉ូហាន២៖៥)

> **មាតារបស់ព្រះអង្គប្រាប់ទៅពួកអ្នកបំរើថា៖ «បើលោកប្រាប់អោយធ្វើអ្វី ចូរធ្វើតាមទៅ»។**

**សកម្មភាពទី២** សូមបង្កើតពាងដែលទឹកបានក្លាយទៅជាស្រាទំពាំងបាយជូរ។

១. ផាត់ពណ៌រូបភាពឱ្យស្អាត។ ២. កាត់ក្រដាសតាមបន្ទាត់ចំនុច។

៣. ដាក់រង្វង់នៅខាងក្រោម រួចត្រួតលើគ្នាត្រង់រូប ● ហើយបង្វិលរង្វង់នោះដោយប្រើប្រដាប់ខ្ទាស់។



រូបភាពរួចរាល់

សម្ភារៈ
កន្ត្រៃ , កូលអេទៀត, ប្រដាប់ខ្ទាស់

